# ឥស្លាម

# ISLAM



# ព័ត៌មានបន្ថែម


@culturalcentercambodia

cacco818140@gmail.com

+85577997733 , +855962336659

ផ្ទះលេខ១០អា ផ្លូវ បេតុង ភូមិទួលសំពៅ សង្កាត់ ទួលសង្កែ
ខណ្ឌ ទួលគោករាជធានីភ្នំពេញ ប្រទេសកម្ពុជា

# ឥស្លាម ( ISLAM )

គោលជំនឿគ្រឹះរបស់ឥស្លាមសាសនិក គឺជាសេចក្តីជំនឿនិងការធ្វើសក្ការៈបូជាសម្រាប់ ព្រះត្រឹមត្រូវពិតតែមួយអង្គគត់។

## សេចក្តីសង្ខេបអំពីសាសនាឥស្លាម

មានសាសនាជាច្រើនបានអះអាង ផងដែរថា ពួកគេក៏ជឿថាមានព្រះតែមួយអង្គគត់ តែទោះបីជាយ៉ាងណា ពួកគេ បានលើកតម្កើងសហព្រះក្លែងក្លាយ (អង្គ ឬ វត្ថុដែលមនុស្សបូជាឬសុំចង់បានសេចក្តីសុខ) ធ្វើជាដៃគូនឹងព្រះពិត (អល់ឡោះ)។ ខាងក្រោមនេះជាឧទាហរណ៍ខ្លះៗ នៃការធ្វើសក្ការៈបូជាព្រះក្លែងក្លាយ

- ការគោរពសក្ការៈបូជា និងការសុំអភ័យទោសព្រះតាមវត្ថុ (ស័ក្តិសិទ្ធិ) ដែលព្រះ(អល់ឡោះ)បានបង្កើត។
- យកគុនលក្ខណៈរបស់ព្រះ ទៅជារូបតំណាងអ្វីមួយ ហើយទទួលយករូបតំណាងនោះធ្វើជាព្រះ។
- រៀបចំពិធីសែនព្រេន ជូនព្រះមុនពេលប្រកួតអ្វីមួយ ។ នេះជាអំពើផ្ទុយនឹងទ្រង់( ព្រះអល់ឡោះ )។

សេចក្តីជំនឿ និង សកម្មភាពខ្លះៗដែលបានរៀបរាប់ខាងលើ គឺជា អំពើធ្វើផ្ទុយស្រឡះនិងគោលជំនឿពិតរបស់ឥស្លាម។

**អល់ឡោះ** *“អល់ឡោះ(ព្រះ) ជានាមផ្ទាល់ខ្លួននៃព្រះពិតតែមួយអង្គគត់”* ពាក្យថា ”អល់ឡោះ” មានកំណើតចេញមកពីភាសាអារ៉ាប់ ។ ហើយពាក្យនេះ ត្រូវបានផ្សំឡើងមានចំនួនពីរព្យាង្គ គឺ”អាល់”និង”អ៊ីឡាហ៍”។ ពាក្យថា”អាល់”មានន័យថា មួយពិតប្រាកដ ហើយពាក្យថា”អ៊ីឡាហ៍”មានន័យថា ព្រះ។ នៅពេលពាក្យពីរនេះផ្គុំគ្នា វាក៏មានន័យថា “ព្រះតែមួយអង្គគត់” ឬ “ព្រះពិតមានតែមួយអង្គគត់ “។

យើងមិនអាចហៅអ្វីផ្សេង ពីទ្រង់(អល់ឡោះ) ថាព្រះបានទេ។ យើងមិនអាចកំណត់ថា ព្រះមានច្រើនឬមានភេទ(ញីឬឈ្មោល)នោះទេ ។នេះសបញ្ជាក់ឲ្យជឿថា ពិភពលោកនិងសត្វលោកទូទៅមានព្រះតែមួយគត់(uniqueness)។ ដូច្នេះយើងមិនគួរយកពាក្យ “ព្រះ” នេះទៅហៅឈ្មោះអ្វីមួយដែលតំណាងឲ្យស្រី ឬញី និងប្រុសឬឈ្មោល ថាជាព្រះរបស់ខ្លួនបានឡើយ។

## សាសនិកឥស្លាមទូទៅជឿថា ព្រះមានតែមួយគត់

- ព្រះ (អល់ឡោះ) មានតែមួយគត់ ហើយគ្មានព្រះផ្សេងណាមួយ ធ្វើជា សម្ព័ន្ធ និងទ្រង់។
- ព្រះ (អល់ឡោះ) គ្មានទេសហការី ហើយក៏គ្មានដៃរភាពស្មើទ្រង់។
- ឥស្លាម បដិសេធរាល់ការយកលក្ខណ: ឬភិនភាគរបស់ព្រះ ឲ្យមានលក្ខណ:ឬទៅជាភិនភាគរបស់មនុស្ស។
- មិនអាចយកអ្វីៗ ដែលព្រះបង្កើត(រាល់ធម្មជាតិទាំងឡាយ) មកប្រដូចនិងទ្រង់(អល់ឡោះ) បានឡើយ។

- គ្មានអ្វីមួយយក មកប្រៀបធៀប និងទ្រង់ (អល់ឡោះ) បានឡើយ។
- គ្មានផ្នែកណាមួយរបស់ព្រះ(អល់ឡោះ)មកស្ថិតគង់ជាមួយអ្នកណា មួយ ។ (សូម្បីតែការដឹងរបស់ទ្រង់គឺជ្រួតជ្រួតជ្រាបលើសសត្វលោកទាំងអស់)

## ព្រះគួរជាទីសរសើរបំផុត

- គ្មានអង្គណាម្នាក់ ឬវត្ថុអ្វីមួយ សមយកមកសសើរនិង ធ្វើសក្ការៈគោរពបូជាឡើយ លើកលែងតែព្រះ(អល់ឡោះ)។
- រាល់សក្ការៈ គោរពបូជានិងការឧទ្ទិសបន់ស្រន់ទៅព្រះ (អល់ឡោះ)តាមរយៈអ្នកមានបុណ្យ ព្យាការី មនុស្ស ឬធម្មជាតិ មានន័យថា អ្នកនោះមិនថ្វាយបង្គំព្រះពិត (អល់ឡោះ)។
- ព្រះ (អល់ឡោះ) ពិតជាបានលឺរាល់អ្នកដែលសរសើរទ្រង់។
- យើងទាំងអស់គ្នា មានទំនាក់ទំនង និងព្រះ (អល់ឡោះ)។
- ឥស្លាមសាសនិកមាន ទំនាក់ទំនងដោយផ្ទាល់និងព្រះ (អល់ឡោះ)មិនចាំបាច់មានសន្ទាការី ឬ អ្នកសម្រុះសម្រួល (ដូចជា រូបបដិមាករ រូបចម្លាក់ផ្នូរ វត្ថុស័ក្តិសិទ្ធិ ព្រះអាទិត្យ ផ្កាយ ព្រះចន្ទ ភ្លើង អារក្សអ្នកតា ដើមឈើ អ្នកមានបុណ្យ អាចារ្យ ទេវតា ឬព្យាការីយេស៊ូ) ទេ។

## ព្រះមហាសែនយុត្តិធម៌បំផុត

- ព្រះ(អល់ឡោះ) កាត់ក្តីឬវិនិច្ឆ័យក្តីយើងទាំងអស់គ្នា ដោយផ្តោតសំខាន
- លើតែសកម្មភាពផ្ទាល់ខ្លួន យើងទាអស់គ្នាតែប៉ុណ្ណោះ ហើយយើងទាំអស

គ្នាគឺនឹងមានទំនួលខុសត្រូវ ទាំងអស់រាល់ទង្វើដែលយើងបានប្រព្រឹត្ត(នៅក្នុងលោកិយ)។

- យើងទាំងអស់គ្នា អាចនឹងដឹងថាខ្លួនឯងខុសប្លែកពីមុន នៅពេលចេះស្វែងរកសេចក្តី ស្រលាញ់នៃព្រះជាម្ចាស់ តាមរយៈ គុណធម៌និងការគោរពតាមក្រិត្យឬ បទបញ្ជារបស់ព្រះ (អល់ឡោះ)ប៉ុននោះ(មិនមែនតាមរយៈជាតិសាសន៍ឬ ទ្រព្យសម្បត្តិនោះទេ)។

## ព្រះដ៏មហាសែនខ្ពង់ខ្ពស់

- ព្រះមានភាពខ្ពង់ខ្ពស់ ហួសពីធម្មជាតិទាំងអស់របស់ទ្រង់។
- ព្រះ (អល់ឡោះ) មានភាពខ្ពង់ខ្ពស់បំផុតលើអ្វីៗគ្រប់យ៉ាង ហើយទ្រង់គឺគ្មានគូប្រៀប។

## ព្រះដ៏មានមេត្តាករុណាបំផុត

- ព្រះ(អល់ឡោះ) មានភាពមេត្តាករុណាច្រើនបំផុត ចំពោះធម្មជាតិទាំងអស់របស់ទ្រង់ លើសពីម្តាយមានក្តីមេត្តាករុណាចំពោះកូនតូចៗរបស់គាត់ទៅទៀត។
- គ្មានអ្នកណាកើតមកភ្លាម មានបាបកម្មស្រាប់នោះទេ។
- ព្រះ (អល់ឡោះ) នឹងអភ័យទោសរាល់អំពើបាប។

## ព្រះដ៏មហាមានអំណាចបំផុត

- ព្រះ (អល់ឡោះ) គ្មានក្រុម ឬបក្សពួកទេ។

- ទស្សនៈដែលថា ព្រះ (អល់ឡោះ)ឈប់សម្រាកនៅថ្ងៃទី៧ នៃថ្ងៃបង្កើតពិភពលោកនោះ គឺគ្មានមូលដ្ឋានទេនៅក្នុងសាសនាឥស្លាម។
- ព្រះ (អល់ឡោះ) គ្រប់គ្រងលើអ្វីៗទាំងអស់។
- ការគោរព ឬ មិនគោរពព្រះ (អល់ឡោះ)មិនបានធ្វើឲ្យអំណាចទ្រង់ប្រែប្រួលឡើងខ្លាំងឬចុះខ្សោយនោះទេ។
- គ្មានស្លឹកឈើណាមួយ ជ្រុះពីដើមរបស់វាដោយគ្មានការអនុញ្ញាតិពីព្រះ (អល់ឡោះ) នោះទេ។

ដើម្បីដឹង និងត្រិះរិះគិតឲ្យសុក្រិត្យបំផុtចំពោះអានុភាពដ៏អស្ចារ្យរបស់ទ្រង់(អល់ឡោះ) គឺយើងត្រូវទន់ភ្លន់ចំពោះទ្រង់។ វិធីនេះហើយដែលទ្រង់ហៅយើង ទាំងអស់គ្នាឲ្យអនុវត្តដើម្បីស្គាល់គាត់ តាមរាល់ គុណលក្ខណៈ និងបណ្តានាមរបស់ទ្រង់(អល់ឡោះ)។ ដើម្បីដឹងពីរិទ្ធិអំណាច ដ៏មហិមាគ្មានព្រំដែននិងអានុភាពដ៏អស្ចារ្យរបស់ទ្រង់ (អល់ឡោះ),ចូរហៅឈ្មោះទ្រង់ និងត្រូវបន្ទាបខ្លួននិងឱនលំទោនចំពោះទ្រង់។ ព្រះ(អល់ឡោះ)មាននាមជាច្រើនខុសៗគ្នាទន្ទឹមនិងគុណលក្ខណៈដ៏ប្រសើររបស់ទ្រង់ ដូចជាឧទាហរណ៍ខាងក្រោម៖

- អង្គដែលបង្កើត និងអង្គទ្រទ្រង់អ្វីៗទាំងអស់។
- អង្គដែលអភ័យទោស និងអង្គលើកលែងទោស។
- អង្គដែលគេលើកសរសើរ
- អង្គដែលដឹងទាំងអស់ និង អង្គមានគតិបណ្ឌិតបំផុត។

- អង្គដែលទទួលយកការបន់ស្រន់។
- អង្គដែលអស្ចារ្យគ្មានគូប្រៀប។

## គម្ពីគួរអាន

ឥស្លាមសាសនិកទូទៅជឿថា គម្ពីរគួរអាន គឺជាពាក្យបន្ទូលរបស់ព្រះ។ គម្ពីរគួរអាននិង រាល់ពាក្យសំដីពិតរបស់ព្យាការីរបស់មូហាំម៉ាត់ (សូមសន្តិភាពមានមកដល់គាត់)គឺជា ប្រភពចំណេះដឹងដ៏សំខាន់នៃសាសនាឥស្លាម។ ខាងក្រោមនេះជាពាក្យបន្ទូលខ្លះៗរបស់ព្រះដែលដកស្រង់ចេញពីគម្ពីរគួរអាន៖

- ទ្រង់គឺអល់ឡោះជាព្រះ ដែលគ្មានព្រះណាត្រូវគេគោរពសក្ការ: ពិតប្រាកដក្រៅពីទ្រង់ (គួរអាន59:22)។
- ចូរអ្នកទាំងអស់គ្នាគោរពសក្ការ:ចំពោះព្រះ(អល់ឡោះ) ហើយកុំគោរពសក្ការ:អ្វីមួយលាយឡំនិងទ្រង់ (គួរអាន4:36)។
- គ្មានអ្វីមកប្រដូចនឹងទ្រង់ បានឡើយ ហើយទ្រង់មហាលឺ និងនិងឃើញបំផុត(គួរអាន42:11)។
- ហើយព្រះ(អល់ឡោះ) របស់អ្នកទាំងអស់គ្នា បានបន្ទូល មកកាន់អ្នកទាំងអស់គ្នាថា”ចូរអ្នក បន់ស្រន់បួងសួងសុំមករកយើងចុះ យើងនឹងទទួលការបន់ស្រន់បួងសួងសុំរបស់ពួកអ្នក(គួរអាន40:60)។
- ដូច្នេះ ចូរអ្នកកុំយកអ្វីមួយមកដាក់គោរពសក្ការ:ជាមួយ និង អល់ឡោះក្នុងពេលអ្នកដឹងច្បាស់ហើយនោះ(គួរអាន2:22)។

ចូរអ្នកនិយាយថាៈ ហេតុអ្វីបានជាពួកអ្នកគោរពសក្ការៈ ផ្សេងពីអល់ឡោះចំពោះអ្វីដែលមិន អាចផ្តល់គ្រោះថ្នាក់និង មិនអាចផ្តល់ផលប្រយោជន៍អ្វីសោះដល់ពួកអ្នកនោះ? (គួរអាន5:76)។

## ព្យាការីមូហាំម៉ាត់

សាសនិកឥស្លាមទូទៅជឿថា មូហាំម៉ាត់ (សូមសន្តិភាពនិងពរជ័យមានមកដល់គាត់) គឺជាព្យាការីចុងក្រោយបង្អស់ ក៏ដូចជាបណ្តាព្យាការីនានាមុនគាត់ដែរ ដែលព្រះបានបញ្ជូនពួកគេមក ដើម្បីហៅមនុស្សជាតិឲ្យស្តាប់តាម ឱវាទព្រះ និងធ្វើសក្ការៈ គោរពចំពោះព្រះ(អល់ឡោះ)តែមួយអង្គគត់។ ខ្លះៗនៃព្យាការីទាំងនោះ មានដូចជា ព្យាការី អាដាំ(Adam),ណូអេ(Noah),យូសេហ្វ (Joseph),យ៉ាកុប(Jacob) , អាប្រាហាំ(Abraham) ដេវីដ(David),មូសេ (Moses), នឹងព្យាការីយេស៊ូ(សូមពរជ័យសន្តិភាពមានមកដល់គាត់ទាំងអស់គ្នា)។

សាសនិកឥស្លាម ទាំងអស់មិនធ្វើសក្កាៈបូជាឬសុំសេចក្តីសុខ ពីព្យាការីមូហាំម៉ាត់ (សូមសន្តិភាពមានមកដល់គាត់)ឡើយ ដូចជា គាត់(ព្យាការីមូហាំម៉ាត់)បានព្រមានទុកមុនថា "ចូរអ្នកកុំធ្វើឲ្យហួសខ្នាតក្នុងការលើកតម្កើងខ្ញុំដូចនិងអ្វីៗដែលគ្រិស្តបរិស័ទបានលើកដម្កើងដល់យេស៊ូ(Jesus) កូនប្រុសម៉ារីឲ្យសោះ ពីព្រោះខ្ញុំគ្រាន់តែជាខ្ញុំបម្រើរបស់ព្រះប៉ុណ្ណោះ។ ដូច្នេះ ចូរអ្នកទាំងអស់គ្នាហៅខ្ញុំថាៈ (មូហាំម៉ាត់)គឺជាខ្ញុំបម្រើរបស់ព្រះ និងជាអ្នកនាំសាររបស់ទ្រង់"។ ឥស្លាមសាសនិកពិតជាជឿថា ព្រះ(អល់ឡោះ)បានបញ្ចុះគម្ពីតូរ៉ា មកឲ្យព្យាការីមូសេ(Moses)និងបានបញ្ចុះគម្ពីគូស្សែលឬបៃប៊ិល(Gospel/Bible)មកឲ្យព្យាការីយេស៊ូ ហើយក៏ដូចគ្នាដែរ សាសនិកឥស្លាមជឿ យ៉ាងច្បាស់ថាព្រះ(អល់

ឡោះ )ក៏បានបញ្ចុះគម្ពីគួរអានមកឲ្យព្យាការីមូហាំម៉ាត់ (សូមសន្តិភាពកើតមានដល់គាត់) ដើម្បីពន្យល់បកស្រាយដល់មនុស្សលោកឲ្យអនុវត្តតាមការប្រៀនប្រដៅតាមគម្ពីគួរអាន។ខាងក្រោមនេះ ជាពាក្យសម្តីខ្លះៗរបស់ព្យាការី( សូមសន្តិភាពមានមកដល់គាត )រួមមាន ៖

ព្រះ(អល់ឡោះ) និងមិនផ្តល់ក្តីមេត្តាករុណាទៅ ចំពោះអ្នកដែលគ្មានក្តីមេត្តាករុណាទៅចំពោះអ្នកផ្សេងពីខ្លួន។

ចូរសម្លឹងទៅចំពោះ បុគ្គលដែលមានភាពនៅក្រោមអ្នក តែកុំសម្លឹងទៅចំពោះ បុគ្គលដែលមានភាពខ្ពង់ខ្ពស់ជាងអ្នក ។ ហេតុដូច អ្នកនិងទទួលភាពរីករាយ (សុភមង្គល) ដ៏ប្រសើរនូវអ្វីដែលទ្រង់(អល់ឡោះ) ប្រទានឲ្យអ្នក។

អ្នកដែលខ្លាំង មិនមែនអ្នកដែលយកឈ្នះមនុស្សដោយប្រើកំលាំងបាយរបស់ខ្លួនទេ ប៉ុន្តែអ្នកដែលខ្លាំងគឺជា អ្នកមានសមត្ថភាពគ្រប់គ្រងកំហឹង របស់ខ្លួនបាននៅក្នុងស្ថានភាពកំហឹង។

ចូរបន្ទាបខ្លួន និងកុំធ្វើអ្វីគ្រោះថ្នាក់ ឬកុំចាត់ទុក ឬ គិតថាខ្លួនឯងមានភាពខ្ពង់ខ្ពស់ជាងអ្នកដ៏ទៃ។

ក្នុងចំណោមអ្នកដែលល្អបំផុត គឺអ្នកដែលមាន ចរិតលក្ខណៈល្អបំផុត។

កុំគិតថាអំពើល្អដ៏តូចតាចបំផុតមិនសំខាន់,សូម្បីតែការញញឹមដាក់គ្នានៅពេលជួបគ្នាក៏ជាអំពើល្អមួយដែរ។

## ការគោរពសក្ការៈបូជា

ឥស្លាម បានបង្រៀនយើងថា មានព្រះតែមួយគត់ដែលសម និងគោរពសក្ការៈ។ដូច្នេះ តើការគោរពសក្ការៈ(worship)ជាអ្វី?អ្នកប្រាជ្ញឥស្លមជាច្រើនបានឲ្យនិយមន័យនៃពាក្យគោរពសក្ការៈថា គឺរាល់ពាក្យសម្ដីនិងសកម្មភាពទាំងឡាយណាដែលកើតមាន ទាំងខាងក្នុងនិងខាងក្រៅត្រូវ និង អ្វីដែលព្រះ (អល់ឡោះ)ចង់បាន។

នៅក្នុងន័យផ្សេងៗទៀត ទស្សនទាននៃការគោរពសក្ការៈ បូជានៅក្នុងសាសនាឥស្លាម គេមិនបានកំណត់ត្រឹមតែការគោរពជាគោលសំខាន់ៗ នៅក្នុងសាសនា មានដូចជា ការថ្វាយបង្គំ(សឡាត)បួស បរិច្ចាកទាន និងការធ្វើបុណ្យធម្មយាត្រា(បុណ្យហាជ្ជនៅទីក្រុង ម៉ាក្កះ ប្រទេស សាអូឌីត)តែប៉ុណ្ណោះទេ តែនៅមានជាច្រើនទៀត។

រាល់ទង្វើ ប្រចាំថ្ងៃរបស់បុគ្គលម្នាក់ៗ ដែល សម្ដែងចេញជាសកម្មភាពស្អាតស្អំដោយចេតនារបស់ខ្លួន មានចិត្តស្មោះត្រង់ ជ្រះថ្លាចង់បាននូវអ្វីដែលព្រះ(អល់ឡោះ) គាប់ហឫទ័យចង់បានគឺជាការគោរសក្ការៈ(worship)។ព្យាការីរបស់ព្រះ (អល់ឡោះ)បានមានប្រសាសន៍ថា ការគោរពគ្នានៅពេលជួបគ្នា គឺជាអំពើសប្បុរសធម៌។ ការប្រកាន់ភាពយុត្តិធម៌ គឺជាអំពើសប្បុរសធម៌។ ការជួយគ្នាគឺជាអំពើសប្បុរសធម៌។ ពាក្យសំដីល្អគឺជាអំពើសប្បុរសធម៌។ រាល់ជំហាននៅលើផ្លូវទៅថ្វាយបង្គំ(សឡាត) គឺជាអំពើសប្បុរសធម៌។ ការយកចេញរបស់នៅតាមផ្លូវដែលអាចធ្វើឲ្យគ្រោះថ្នាក់ដល់អ្នដំណើរ(បន្លា ដែកគោល ដុំថ្ម ដបទឹកសុទ្ធ....) គឺជាអំពើសប្បុរសធម៌។សូម្បីតែការរក ប្រាក់តាមផ្លូវព្រះចង់បាន ហើយប្រសិនជាការរកប្រាក់នោះសមហេតុសមផល (ឧ:ការធ្វើការដើម្បីចិញ្ចឹមគ្រួសារ) ក៏គេអាចរាប់បញ្ចូលថា ជាអំពើគោរពសក្ការៈ(worship)ចំពោះព្រះដែរ។

តែប្រសិនជាបុគ្គលនោះធ្វើការចង់បានតែគេសរសើរ ឬចង់បានល្បីឈ្មោះនោះ ឥស្លាមមិនអាចចាត់ទុកវាជា ទង្វើនៃការគោរពសក្ការៈ ចំពោះព្រះ(អល់ឡោះ) បានឡើយ។ចំនុចដែល បានពណ៌នាខាងលើប្រហែលជាអាចនិយាយបានថា វាជាការចម្លែកចំពោះអ្នកដែលមានទស្សនៈថា សាសនាមានទំនាក់ទំនងផ្ទាល់ខ្លួនរវាងបុគ្គលនិងព្រះតែប៉ុណ្ណោះ ហើយក៏គិតថាមិនបាន ប៉ះពាល់លើសកម្មភាពទាំងនោះ ជាពិសេសគ្មានទំនាក់ទំនងនិងរាល់ពិធីគោរព ជាប្រចាំនៅក្នុងសាសនា (rituals)។ ទោះបីជាយ៉ាងណាក៏ដោយ, សម្រាប់សាសនិកឥស្លាមទូទៅវិញគិតថា ឥស្លាមមិនត្រឹមតែជាសាសនាប៉ុណ្ណោះទេ តែវាជាវិថីនៃជីវិតទាំងមូលរបស់មនុស្សជាតិ។

## សម្រាប់រាល់ឯកសារបន្ថែមអំពីឥស្លាម:

- ទាញយកជាវីឌីអូ : www.thedeenshow.com
- អំពីព្យាការីមូហាំម៉ាត់ : www.rasoulallah.net
- អាចជជែក(chat)តាមអនឡាញ : www.islamtomorrow.com
- ទាញយកសៀវភៅ : www.islamicmessage.net/cims/default.aspx

